ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំឆ្នាំ២០១៩-២០២០ និងទិសដៅអនុវត្តឆ្នាំ២០២០-២០២១



សន្និបាតកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ថ្ងៃ១៩-២០ និង២៣ ខែមីនា ឆ្នាំ២០២០

# មាតិកា


I- សេចក្តីផ្តើម ........ 1

II- គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ........ 3

III- លទ្ធផលជារួម ........ 16

IV- លទ្ធផលតាមអនុវិស័យ ........ 18

១.បង្កើនផលិតភាពនិងពិពិធកម្មដំណាំកសិកម្ម ........ 18

២.ការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ........ 41

៣.លទ្ធផលនៃការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍន៍វារីវប្បកម្ម ........ 57

៤.លទ្ធផលនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ ........ 59

៥.លទ្ធផលនៃការពង្រឹងសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ........ 64

V- បញ្ហាប្រឈម ........ 92

VI- ទិសដៅអនុវត្ត ........ 93

១. ផែនការផលិតកម្មដំណាំស្រូវដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ........ 93

២. ផែនការផលិតកម្មដំណាំកៅស៊ូ ........ 95

៣. ផែនការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ........ 96

៤. ផែនការផ្នែកជលផល ........ 97

៥. ផែនការផ្នែកព្រៃឈើ ........ 98

VII- សេចក្តីសន្និដ្ឋាន ........ 99

ឧបសម្ព័ន្ធ

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៩-២០២០
# និងទិសដៅអនុវត្តឆ្នាំ២០២០-២០២១

## I- សេចក្តីផ្តើម

វិស័យកសិកម្មជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពជាគន្លឹះ របស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។** វិស័យនេះបាននិងកំពុងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសន្តិសុខស្បៀង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច ការលើកកម្ពស់ផលិតកម្មសត្វនិងសុខភាពសត្វ ការគ្រប់គ្រងធនធានជលផលនិងអភិវឌ្ឍន៍វារីវប្បកម្ម ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ រួមទាំងការបង្កើនប្រសិទ្ធភាពសេវាគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស។

ក្នុងន័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការបន្តធ្វើទំនើបកម្មវិស័យកសិកម្ម ដោយបានអនុវត្តវិធានការគោលនយោបាយនានា សំដៅបង្កើនផលិតភាពលើមុខដំណាំដែលមានតម្លៃទីផ្សារខ្ពស់ ធ្វើពិពិធភាវូបនីយកម្មកសិកម្ម និងកសិ-ពាណិជ្ជកម្ម។ ជាមួយគ្នានេះ ក្រសួងបានជំរុញការអនុវត្តវិធានការចាំបាច់មួយចំនួនទៀតរួមមាន៖ ការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធគាំទ្រដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនគុណភាពនៃការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ជំរុញការស្រាវជ្រាវបច្ចេកទេសកសិកម្មសំដៅបង្កើនទិន្នផលដំណាំ និងធន់នឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនប្រសិទ្ធភាពការប្រើប្រាស់ដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ព្រមទាំងការកសាង និងពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័នដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មឱ្យមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ក្រសួងក៏បានយកចិត្តទុកដាក់ខ្ពស់អំពីការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ព្រមទាំងខិតខំយ៉ាងខ្លាំងក្លាលើការអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសសមស្របក្នុងការគ្រប់គ្រងប្រើប្រាស់ធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។ ការខិតខំប្រឹងប្រែងទាំងអស់នេះ គឺក្នុងទិសដៅចូលរួមចំណែកបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាការជួយបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ការបន្តជំរុញការធ្វើកសិ-ពាណិជ្ជកម្ម និងការបង្កើនចំណូលជាតិ។

គួរកត់សម្គាល់ថា ផលិតកម្មដំណាំស្រូវមានការវិវឌ្ឍឈានឡើងជាលំដាប់ គឺអាស្រ័យដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិនានា អាជ្ញាធរថ្នាក់ក្រោមជាតិ និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ ជាពិសេសការប្តូរទម្លាប់ពីការផលិតសម្រាប់ហូបចុកមកជាការផលិតសម្រាប់ពាណិជ្ជកម្ម និងការនាំចេញ។ ការសម្រេចបានក្នុងការបង្កើនផលិតភាពដំណាំស្រូវ បណ្តាលមកពីកត្តាសំខាន់ៗមួយចំនួនដូចជា ការផ្លាស់ប្តូរពូជស្រូវដែលមានទិន្នផលខ្ពស់ ដែលជាលទ្ធផលទទួលបានពីការពិសោធន៍ស្រាវជ្រាវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ជាពិសេសការពង្រីកកាន់តែមានប្រសិទ្ធភាពលើការធ្វើស្រែបង្ហាញតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ការអនុវត្តបច្ចេកទេសគ្រប់គ្រងដី ដើម្បីបង្កើនជីជាតិ និងទិន្នផល ការបង្កើនការស្រាវជ្រាវនិងអភិវឌ្ឍន៍ពូជស្រូវដែលស្របនឹងលក្ខណៈដី អាកាសធាតុ ការកំណត់ប្រភេទពូជសំខាន់ៗស្របតាមតម្រូវការទីផ្សារ។

ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តនូវយន្តការអន្តរាគមន៍ ដើម្បីដោះស្រាយបញ្ហាហេដ្ឋារចនាសម្ព័ន្ធឡសម្ងួត និងឃ្លាំងស្តុកស្រូវ ក៏ដូចជាទុនបង្វិល ដើម្បីការពារផលប្រយោជន៍កសិករ តាមរយៈការការពារ

ស្ថិរភាពនៃថ្លៃស្រូវ គឺទ្រទ្រង់ថ្លៃស្រូវកុំឱ្យធ្លាក់ចុះខ្លាំងពេកហួសពីថ្លៃទីផ្សារដោយមិនសមហេតុផល។ ទន្ទឹមនឹងការប្រឈមស្ថានភាពនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញនូវសេចក្តីណែនាំស្តីពីវិធានការលើកកម្ពស់ផលិតកម្ម និងធុរកិច្ចស្រូវអង្ករ ដោយផ្តោតលើការផលិតនិងនាំចេញអង្ករក្រអូប ការកាត់បន្ថយថ្លៃដើមផលិតកម្ម ការជំរុញឱ្យអ្នកប្រមូលទិញស្រូវត្រូវបន្តធ្វើការទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីទទួលបានឥណទានប្រមូលទិញស្រូវពីកសិករ សហគមន៍កសិកម្ម និងជំរុញឱ្យសហព័ន្ធស្រូវអង្ករកម្ពុជាយកចិត្តទុកដាក់លើការបង្កើនសមត្ថភាពកែច្នៃអង្ករឱ្យមានគុណភាពបន្ថែមទៀតសម្រាប់បម្រើឱ្យទីផ្សារអន្តរជាតិ។

បច្ចុប្បន្ននេះ ក្រសួងបានកត់សម្គាល់ឃើញថា ប្រជាកសិករយើងកំពុងផ្លាស់ប្តូរទម្លាប់ពីការផលិតសម្រាប់បម្រើសេចក្តីត្រូវការផ្ទាល់ខ្លួន មកជាការផលិតដើម្បីលក់ ព្រោះមានតម្រូវការទីផ្សារនិងផលចំណេញខ្ពស់។ ផ្អែកលើការផ្លាស់ប្តូរនេះ ក្រសួងអាចវាយតម្លៃបានថា សហគមន៍កសិកម្មកំពុងក្លាយជាកម្លាំងចលករមួយយ៉ាងសំខាន់ ដែលនាំឱ្យមានលទ្ធផលជាវិជ្ជមាននៅក្នុងសង្គមជនបទកម្ពុជា។ កត្តានេះបង្ហាញឱ្យឃើញថា កសិករយើងបាននិងកំពុងប្រែក្លាយខ្លួនចេញពី **“កសិករទៅជាកសិ-ពាណិជ្ជករ”** ដើម្បីទទួលបានតម្លៃបន្ថែមក្នុងជីវភាពរស់នៅរបស់ខ្លួន។

ជាមួយគ្នានេះ ស្ថាប័នជាច្រើន ទាំងរដ្ឋ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលបាន និងកំពុងផ្តល់សេវាកម្ម ដើម្បីបង្កើនចំណេះដឹងនិងចំណេះធ្វើដល់កសិករនៅមូលដ្ឋាន ហើយក៏មានកសិករជាច្រើនបានក្រេបជញ្ជក់យកបទពិសោធន៍ និងទេពកោសល្យទាំងអស់នេះយកទៅអនុវត្តប្រកបដោយភាពឧស្សាហ៍ព្យាយាម និងច្នៃប្រឌិត ដោយទទួលបានលទ្ធផលជាផ្លែផ្កាយ៉ាងត្រចះត្រចង់នៅក្នុងតំបន់ជាច្រើនទៅតាមអនុវិស័យនីមួយៗ។ វិស័យឯកជនបានតម្រង់ទិសការផលិតឆ្ពោះទៅរកទីផ្សារនាំចេញ តាមរយៈការបង្កើនសមត្ថភាពកែច្នៃ ធានាបានទាំងគុណភាពនិងបរិមាណ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារអន្តរជាតិ ពិសេសការនាំចេញចេកអំបូងលឿង ស្វាយកែវរមៀត ម្រេច ដំឡូងមី និងផលិតផលកសិកម្មសំខាន់ៗដទៃទៀត មានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់។

ការដាំដុះកៅស៊ូនៅកម្ពុជាមានការកើនឡើងជាលំដាប់ អាស្រ័យដោយស្ថានភាពនយោបាយ សន្តិសុខល្អប្រសើរ សក្តានុពលនៃដីសមស្រប និងគោលនយោបាយទីផ្សារសេរី លើការលក់ដូរផលិតផលកៅស៊ូគ្រួសារក្នុងស្រុក។ ទន្ទឹមនឹងនេះ ការចូលរួមពីផ្នែកឯកជនក្នុងការធ្វើវិនិយោគលើដីសម្បទានសេដ្ឋកិច្ច និងកៅស៊ូគ្រួសារ បានធ្វើឱ្យផ្ទៃដីដាំដុះកៅស៊ូកើនឡើង ទោះជាស្ថានភាពទីផ្សារនិងតម្លៃកៅស៊ូ ព្រមទាំងកម្លាំងពលកម្មមានការប្រឈមក៏ដោយ។

ផលិតកម្មសត្វទាំងលក្ខណៈគ្រួសារនិងពាណិជ្ជកម្មនៅកម្ពុជា ក៏មានការវិវឌ្ឍគួរឱ្យកត់សម្គាល់ ទាំងបរិមាណសត្វ និងបែបផែនផលិតកម្ម។ ការរីកចម្រើនទាំងអស់នេះ គឺជាលទ្ធផលនៃការស្រាវជ្រាវ និងការយល់ដឹងអំពីបច្ចេកទេសចិញ្ចឹមសត្វ ការជ្រើសរើសនិងការបង្កាត់ពូជសត្វ ការផលិតចំណីសត្វ និងការផ្តល់សេវាថែទាំសុខភាពសត្វ។ ជាមួយគ្នានេះ ការអនុវត្តច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ដែលបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ត្រូវបាននិងកំពុងអនុវត្តយ៉ាងមានប្រសិទ្ធភាព។ ការអភិវឌ្ឍផ្នែកផលិតកម្មសត្វ ពិសេសផលិតកម្មគោពូជកូនកាត់ដែលផ្តល់តម្លៃខ្ពស់ និងលើកកម្ពស់សុខភាពសត្វនៅកម្ពុជាបាន និងកំពុងជំរុញយ៉ាងផុលផុស។ ជាងនេះទៅទៀត ការទប់ស្កាត់ចលនាសត្វខុសច្បាប់ត្រូវបានអនុវត្តយ៉ាងយកចិត្តទុកដាក់ ហើយការទប់ស្កាត់ជំងឺឆ្លងសត្វ ក៏ត្រូវបានពង្រឹងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ការកែទម្រង់ស៊ីជម្រៅអនុវិស័យជលផលត្រូវបន្តបានអនុវត្តយ៉ាងសកម្ម។ កំណែទម្រង់នេះ បានធ្វើឱ្យប្រជាជនទូទៅ ជាពិសេសអ្នកប្រកបរបរនេសាទជាលក្ខណៈគ្រួសារ អាចធ្វើអាជីវកម្មបានទូលំទូលាយជាងមុន។ រហូតមកដល់ពេលនេះ យើងបានបង្កើតសហគមន៍នេសាទចំនួន៥១៦ ដើម្បីគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាព តាមរយៈការអនុវត្តទិសស្លោក **“សហគមន៍នេសាទ គ្មានបទល្មើស”** ក្នុងគោលបំណងពង្រឹងសហគមន៍នេសាទឱ្យបានរឹងមាំ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមគ្រប់គ្រង និងថែរក្សាការពារធនធានជលផលឱ្យបានគង់វង្ស។ ការ